# ព័ត៌មានដែលត្រូវការដើម្បីដាក់ពាក្យសម្រាប់ភាពគ្មានការងារធ្វើនៃរដ្ឋ Maine

វីដេអូណែនាំអំពីជំហាននីមួយៗអាចរកបាននៅលើ You Tube (មានតែជាភាសាអង់គ្លេសប៉ុណ្ណោះ)

ការបង្កើតគណនី ReEmployME របស់អ្នក៖ https://www.youtube.com/watch?v=7ySVbKf9vi8

ការដាក់ពាក្យបណ្តឹងទាមទារដំបូងរបស់អ្នក៖ https://www.youtube.com/watch?v=uW0qlXfU9lQ

ការដាក់ពាក្យបណ្តឹងទាមទារប្រចាំសប្តាហ៍របស់អ្នក៖ https://www.youtube.com/watch?v=tu0M9w-gWS4

ប្រសិនបើអ្នកមិនមានអ៊ីមែលទេ សូមបង្កើតគណនីអ៊ីមែលនៅក្នុង Gmail (ឬ Yahoo, Outlook)។
ដើម្បីបង្កើតគណនីអ្នកប្រើថ្មីជាមួយ ReEmployME សូមចូលទៅកាន់ www.maine.gov/reemployme ហើយបង្កើត៖

**ឈ្មោះចូល៖ ________________________________________**

**ពាក្យសម្ងាត់៖ ________________________________________**

**សំខាន់! ផ្ទៀងផ្ទាត់អាសយដ្ឋានអ៊ីមែលរបស់អ្នកបន្ទាប់ពីអ្នកបង្កើតគណនីរបស់អ្នក៖**

1. ពីគណនីរបស់អ្នក សូមទៅកាន់ ការរក្សាអត្ថប្រយោជន៍ > ធ្វើបច្ចុប្បន្នភាពប្រវត្តិរូបអ្នកទាមទារ > ផ្ទៀងផ្ទាត់អ៊ីមែល

2. នៅលើអេក្រង់បន្ទាប់ អ្នកអាចបញ្ចូលលេខកូដផ្ទៀងផ្ទាត់របស់អ្នកដែលបានទទួលនៅអាសយដ្ឋានអ៊ីមែលនៅក្នុងឯកសារ ដើម្បីធ្វើឱ្យអ៊ីមែលរបស់អ្នកដំណើរការ ឬចុចលើពាក្យ 'ទីនេះ' ដើម្បីបង្កើត និងផ្ញើលេខកូដថ្មីទៅអាសយដ្ឋានអ៊ីមែលនៅក្នុងឯកសារ។ (ប្រសិនបើអ្នកត្រូវការលេខកូដផ្ទៀងផ្ទាត់ផ្សេងទៀត សូមចុច 'ទីនេះ'។ អ៊ីមែលនឹងត្រូវបានផ្ញើមកអ្នកជាមួយលេខកូដផ្ទៀងផ្ទាត់ថ្មី។)

3. ប្រសិនបើលេខកូដផ្ទៀងផ្ទាត់ថ្មីត្រូវបានផ្ញើទៅអ្នក សូមត្រលប់ទៅជំហានទី 2 នៅលើអេក្រង់ដដែល ហើយបញ្ចូលលេខកូដនេះដើម្បីបញ្ចប់ការធ្វើឱ្យដំណើរការ។

## ដើម្បីដាក់ពាក្យសម្រាប់ភាពគ្មានការងារធ្វើ អ្នកត្រូវផ្តល់ដូចខាងក្រោម៖

1. ឈ្មោះតាមផ្លូវច្បាប់ (នាមខ្លួន អក្សរកាត់នាមកណ្តាល នាមត្រកូល)
2. អាសយដ្ឋានផ្ញើសំបុត្របច្ចុប្បន្នរបស់អ្នក
3. លេខទូរសព្ទរបស់អ្នក
4. អ៊ីមែល
5. ភេទ (ប្រុស/ស្រី)
6. ថ្ងៃខែឆ្នាំកំណើត (ខែ, ថ្ងៃ, ឆ្នាំ)
7. លេខសន្តិសុខសង្គម (SSN)
8. ប្រសិនបើអ្នកមិនមែនជាពលរដ្ឋអាមេរិក អ្នកត្រូវតែមាន៖
    a. ឋានៈជាអ្នករស់នៅអចិន្ត្រៃយ៍ស្របច្បាប់ (អ្នកកាន់ "បណ្ណបៃតង")
    b. ឯកសារអនុញ្ញាតឱ្យធ្វើការងាររបស់សហរដ្ឋអាមេរិក ("បណ្ណការងារ") ឬ

c. កំណត់ត្រាអំពីការមកដល់/ការចាកចេញដែលដាក់ថា “មានការអនុញ្ញាតឱ្យធ្វើការងារ” (“ បណ្ណ








I-94”)។

## លេខជនបរទេស

- ប្រសិនបើអ្នកមានបណ្ណបៃតង ឬបណ្ណការងារ សូមដាក់លេខ USCIS/ លេខជនបរទេសរបស់អ្នកនៅកន្លែងដែលការដាក់ពាក្យតាមអនឡាញដាក់ថា "លេខជនបរទេស"។

- ប្រសិនបើអ្នកមានបណ្ណ I-94 “មានការអនុញ្ញាតឱ្យធ្វើការងារ” សូមសរសេរលេខបណ្ណ I-94 ដែលមាន 11 ខ្ទង់របស់អ្នកនៅកន្លែងដែលការដាក់ពាក្យតាមអនឡាញដាក់ថា "លេខជនបរទេស"។

## កាលបរិច្ឆេទផុតកំណត់នៃឯកសាររបស់អ្នក

សូមដាក់កាលបរិច្ឆេទដែលឯកសារខាងលើរបស់អ្នកនឹងផុតកំណត់។

**សម្គាល់៖** ប្រសិនបើឯកសាររបស់អ្នកមិនមានកាលបរិច្ឆេទផុតកំណត់ សូមដាក់កាលបរិច្ឆេទដែលមានរយៈពេលមួយឆ្នាំគិតចាប់ពីថ្ងៃដែលអ្នកដាក់ពាក្យសុំ។

- **ឧទាហរណ៍៖** អ្នកដាក់ពាក្យស្នើសុំអត្ថប្រយោជន៍នៅថ្ងៃទី 4/1/2020។ ការផុតកំណត់គួរតែនៅថ្ងៃទី៖ 4/1/2021.

## សិទ្ធិទទួល

- អ្នកត្រូវតែទទួលការអនុញ្ញាតឱ្យធ្វើការនៅសហរដ្ឋអាមេរិកដោយស្របច្បាប់នៅពេលអ្នកទទួលបានប្រាក់ឈ្នួលគិតតាមរយៈពេលរបស់អ្នក។
- អ្នកត្រូវតែទទួលការអនុញ្ញាតឱ្យធ្វើការស្របច្បាប់ខណៈពេលដែលអ្នកទាមទារអត្ថប្រយោជន៍សម្រាប់ភាពគ្មានការងារធ្វើ។
- លេខសន្តិសុខសង្គម និង/ឬលេខជនបរទេសរបស់អ្នកនឹងត្រូវបានបញ្ជាក់ជាមួយមូលដ្ឋានទិន្នន័យសហព័ន្ធ ដូច្នេះត្រូវប្រាកដថាបញ្ចូលព័ត៌មានពេញលេញដែលត្រូវគ្នានឹងឯកសារទាំងនេះ។

## ព័ត៌មានដែលត្រូវការសម្រាប់ប្តីឬប្រពន្ធ និងអ្នកនៅក្នុងបន្ទុក (កូនៗ)

- **ឈ្មោះតាមផ្លូវច្បាប់** (នាមខ្លួន អក្សរកាត់នាមកណ្តាល នាមត្រកូល) របស់ប្តីឬប្រពន្ធ/កូន
- លេខសន្តិសុខសង្គម
- ទំនាក់ទំនង
- ថ្ងៃខែឆ្នាំកំណើត

## ព័ត៌មានអំពីនិយោជក/ប្រវត្តិការងារ

អ្នក ត្រូវដាក់ឈ្មោះនិយោជករបស់អ្នកទាំងអស់ក្នុងរយៈពេល 18 ខែចុងក្រោយ

ប្រសិនបើអ្នកមានការងារច្រើនជាងមួយ ឬនិយោជកច្រើនជាងម្នាក់

1. ឈ្មោះនិយោជក (ផ្តល់ ឈ្មោះពេញរបស់ក្រុមហ៊ុន)
2. អាសយដ្ឋាននិយោជក (ផ្តល់អាសយដ្ឋានផ្ញើសំបុត្រពេញលេញរបស់ក្រុមហ៊ុនដែលមានលេខកូដតំបន់)
    a. លេខទូរសព្ទនិយោជក
    b. ឈ្មោះរបស់អ្នកត្រួតពិនិត្យ *(វាមិនត្រូវបានគេសួរទេ ប៉ុន្តែអាចមានប្រយោជន៍ដែលត្រូវដឹងបើសិនជាអ្នកមានសំណួរ)*
3. លេខទំនាក់ទំនង ឬអ៊ីមែលសម្រាប់អ្នកត្រួតពិនិត្យ *(វាមិនត្រូវបានគេសួរទេ ប៉ុន្តែអាចមានប្រយោជន៍ដែលត្រូវដឹងបើសិនជាអ្នកមានសំណួរ)*

## តើអ្នកធ្វើការនៅទីនោះរយៈអស់ពេលប៉ុន្មាន ហើយតើអ្នកចាប់ផ្តើមនៅពេលណា?

1. កាលបរិច្ឆេទការងារថ្មីបំផុតរបស់អ្នក/ពេលអ្នកធ្វើការ
    a. តើអ្នកចាប់ផ្តើមការងារនេះនៅពេលណា? ខែ, ថ្ងៃ, ឆ្នាំ
    b. តើពេលណាអ្នកបានឈប់ពីការងារនេះ (ត្រូវបានបញ្ឈប់ពីការងារ)? ខែ, ថ្ងៃ, ឆ្នាំ
2. ចំនួនម៉ោងក្នុងមួយសប្តាហ៍ដែលអ្នកធ្វើការងារនេះ? ពេញម៉ោង/ក្រៅម៉ោង?

## តើអ្នកបានទទួលប្រាក់ឈ្នួលប៉ុន្មាន?

1. តើបានប្រាក់ឈ្នួលប៉ុន្មានក្នុងមួយម៉ោង? ប្រាក់ឈ្នួលតាមម៉ោង?
2. តើបានប្រាក់ឈ្នួលដុលប៉ុន្មានក្នុងមួយសប្តាហ៍ (សរុបមុនគិតពន្ធ)
3. តើបានប្រាក់ឈ្នួលសុទ្ធប៉ុន្មានក្នុងមួយសប្តាហ៍ (ចំនួនប៉ុន្មានដែលអ្នកបានទទួលពិតប្រាកដ)។ (សូមមើលកន្ទុយមូលប្បទានប័ត្រ ឬបណ្ណទូទាត់ដើម្បីផ្ទៀងផ្ទាត់)
4. <u>ប្រាក់ឈ្នួលដុល៖</u>
<u>រាយការណ៍ពីចំនួនដុលនៃប្រាក់ចំណូលរបស់អ្នកសម្រាប់សប្តាហ៍នីមួយៗដែលអ្នកធ្វើការខណៈពេលដាក់ពាក្យបណ្តឹងទាមទារ ក៏ដូចជាការខកខានមិនបានរាយការណ៍អំពីប្រាក់ឈ្នួល (ប្រាក់បំណាច់, ប្រាក់ឈ្នួលថ្ងៃឈប់សម្រាក, ប្រាក់ឈ្នួលថ្ងៃវិស្សមកាល, ប្រាក់រង្វាន់) អាចបណ្តាលឱ្យមានការកំណត់នូវការលួចបន្លំ។</u>

## តើអ្នកចង់ទទួលបានប្រាក់ឈ្នួលយ៉ាងដូចម្តេច?

អ្នកនឹងត្រូវបានគេសួរនូវវិធីទូទាត់ដែលអ្នកពេញចិត្ត៖ ការដាក់ប្រាក់ដោយផ្ទាល់ចូលក្នុងគណនីសន្សំ ឬគណនីចរន្តផ្ទាល់ខ្លួនរបស់អ្នកនៅធនាគារ ឬបណ្ណទូទាត់អេឡិចត្រូនិក (EPC)។
នេះគឺជាបណ្ណឥណពន្ធវីសាពីធនាគារសហរដ្ឋអាមេរិក។

### ប្រសិនបើអ្នកចង់ទទួលប្រាក់ឈ្នួលដោយការដាក់ប្រាក់ដោយផ្ទាល់ទៅក្នុងធនាគារ អ្នកនឹងត្រូវការ៖

- ឈ្មោះរបស់បុគ្គលនៅលើគណនីធនាគារ
- ឈ្មោះធនាគារ
- អាសយដ្ឋានធនាគារ
- លេខទូរសព្ទធនាគារ
- គណនីសន្សំ ឬចរន្ត
- លេខគណនី
- "លេខទីតាំងបើកគណនី" ធនាគារ (អាចរកឃើញនៅលើមូលប្បទានប័ត្រ)

ប្រសិនបើអ្នកចង់ទទួលបានការទូទាត់ដោយប្រើបណ្ណទូទាត់អេឡិចត្រូនិក (ឥណពន្ធវីសា) អ្នកនឹងត្រូវបានផ្ញើវីសាកាត។ ការណែនាំសម្រាប់ការប្រើប្រាស់បណ្ណត្រូវបានផ្តល់ជូនជាមួយបណ្ណ។

សូមចូលទៅកាន់ www.maine.gov/reemployme ហើយចុចលើជម្រើសទូទាត់ នៅក្រោមផ្នែក "ស្វែងយល់អំពី" សម្រាប់ព័ត៌មានបន្ថែម។

## ការពិចារណាអំពីពន្ធ

អ្នកនឹងត្រូវបានសួរថា តើអ្នកចង់កាត់ទុកពន្ធក្នុងអំឡុងពេលដាក់ពាក្យ ដំបូងរបស់អ្នកដើម្បីស្នើសុំអត្ថប្រយោជន៍ឬអត់ (យើង *ផ្តល់អនុសាសន៍ឱ្យអ្នកកាត់ទុកពន្ធ ប្រសិនបើអ្នកអាចដូច្នេះមិនមានការបង់ពន្ធ នៅពេលក្រោយសម្រាប់ការទូទាត់ប្រាក់ឈ្នួលសម្រាប់ភាពគ្មានការងារធ្វើណាមួយដែលអ្នកទទួលទេ*)។ 10% ត្រូវបានកាត់ទុកសម្រាប់ពន្ធសហព័ន្ធ? 5% ត្រូវបានកាត់ទុកសម្រាប់ពន្ធរដ្ឋ?

- ប្រសិនបើបច្ចុប្បន្នអ្នកកំពុងទទួលបានការធានារ៉ាប់រងសន្តិសុខសង្គម (SSI) ឬកំពុងទទួលបានជំនួយជាសាធារណៈសម្រាប់កូនរបស់អ្នក (TANF) អ្នក **អាច** ត្រូវបានលើកលែងពីការកាត់ពន្ធដោយស្វ័យប្រវត្តិ។

**នៅពេលដែលអ្នកបានដាក់ពាក្យទាមទាររួចហើយ អ្នកនឹងទទួលបានលេខបញ្ជាក់មួយ និងអ៊ីមែលបញ្ជាក់មួយ នៅពេលដែលការទាមទាររបស់អ្នកត្រូវបានទទួលយក។** ប្រសិនបើអ្នកមិនបានទទួលលេខបញ្ជាក់ទេ អ្នកមិនបានបញ្ចប់ដំណើរការដាក់ពាក្យទាមទារនេះទេ។

**អ្នកត្រូវតែដាក់លិខិតបញ្ជាក់រៀងរាល់សប្តាហ៍ដែលអ្នកចង់ទាមទារអត្ថប្រយោជន៍សម្រាប់ភាពគ្មានការងារធ្វើ។ អ្នកអាចធ្វើដូច្នេះបានតាមរយៈគណនី ReEmployME អនឡាញរបស់អ្នក ឬតាមទូរសព្ទ។**

## ប្រភព

**សំណួរសួរញឹកញាប់អំពីភាពគ្មានការងារធ្វើ៖**
https://www.maine.gov/labor/docs/2020/covid19/covidfaqandui.pdf
**គេហទំព័រស្តីពីភាពគ្មានការងារធ្វើរបស់ MDOL៖** https://www.maine.gov/unemployment/
**ព័ត៌មានអំពីភាពគ្មានការងារធ្វើដោយសារ COVID-19៖** https://www.maine.gov/labor/covid19/
**ការដាក់ពាក្យបណ្តឹងទាមទារតាមអនឡាញ៖** **www.maine.gov/reemployme**

**ម៉ោងធ្វើការនៃការិយាល័យសេវាកម្មអត្ថប្រយោជន៍៖** ច័ន្ទ – សុក្រ ពីម៉ោង 8:00 ព្រឹកដល់ម៉ោង 5:00 ល្ងាច
**ម៉ោងសេវាបម្រើអតិថិជន៖** ច័ន្ទ – សុក្រ ពីម៉ោង 8:00 ព្រឹកដល់ម៉ោង 12:30 ថ្ងៃត្រង់

**លេខទូរសព្ទសេវាបម្រើអតិថិជន៖** **1-800-593-7660**
**សេវាបម្រើអតិថិជនតាមអនឡាញ៖** www.maine.gov/labor/contact
(ជ្រើសរើសប៊ូតុងភាពគ្មានការងារធ្វើ)
**ស្វែងរកមជ្ឈមណ្ឌលអាជីពក្នុងតំបន់/ជដែកផ្ទាល់៖**
https://www.mainecareercenter.gov/locations/index.shtml